# និន្នាការសេដ្ឋកិច្ចសង្គម

## Socio-Economic Trends

**ប្រចាំខែ កក្កដា-សីហា ឆ្នាំ ២០១៥/July-August, 2015**

## មាតិកានុក្រម


| | ទំព័រ |
|---|---|
| ខ្លឹមសារសង្ខេប/Executive summary | ២ |
| ១. និន្នាការសេដ្ឋកិច្ចកម្ពុជា/Cambodia economic trends | ៤ |
| ១.១. សន្ទស្សន៍ថ្លៃទំនិញ/Consumer price index | ៤ |
| ១.២. វិស័យហិរញ្ញវត្ថុ /Finance | ៧ |
| ១.៣. វិស័យពាណិជ្ជកម្ម/Trades | ១២ |
| ១.៤. ការអនុវត្តថវិកា/Budget execution | ១៦ |
| ១.៥. វិស័យវិនិយោគឯកជន/Private investment | ១៨ |
| ១.៦. វិស័យទេសចរណ៍/Tourism | ១៩ |
| ១.៧. វិស័យសំណង់/Construction | ២១ |
| ២. និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ/International commodities price | ២២ |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price average: Brent; Dubai; WTI) | ២២ |
| ២.២. ថ្លៃអង្ករ (Rice price: 5 %; 25 %; 100 % broken) | ២២ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: SGP/MYS; TSR20) | ២២ |
| ៣. ឧបសម្ព័ន្ធ | ២៤ |


រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៥

**ប្រធាននាយកដ្ឋានស្ថិតិ**

## ខ្លឹមសារសង្ខេប/Executive summary

១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញ ក្នុងខែ កក្កដា ឆ្នាំ ២០១៥ បានកើនឡើង ០,៥ ភាគរយ ធៀបនឹងខែកន្លងទៅ ឬ បានកើនឡើង ០,៨ ភាគរយ ធៀបនឹង១២ខែមុន ដោយសារមានការកើនឡើងសន្ទស្សន៍ថ្លៃអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង ថ្លៃសំលៀកបំពាក់និងស្បែកជើង ថ្លៃផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត ថ្លៃគ្រឿងសង្ហារឹមសម្ភារៈប្រើប្រាស់និងការថែទាំ ថ្លៃសុខាភិបាល ថ្លៃគមនាគមន៍ និងថ្លៃភោជនីយដ្ឋាន ។ ចំពោះសន្ទស្សន៍ថ្លៃទំនិញដែលបានធ្លាក់ចុះ ដូចជា សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ ក្នុងខណៈដែលសន្ទស្សន៍ថ្លៃទំនិញផ្សេងៗទៀតស្ថិតនៅនឹង ។

២. រយៈពេល៥ខែដើមឆ្នាំ ២០១៥ រូបិយវត្ថុទូទៅ (M2) ក្នុងមួយខែ មានកំណើនជាមធ្យម ១,១ ភាគរយ ក្នុងនោះ ប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស បានកើន ១,៣ ភាគរយ ចំណែករូបិយវត្ថុ (M1) មាននិន្នាការថយចុះបន្តិចមកវិញ ។ ជារួម ស្ថានភាពរូបិយវត្ថុ បានរក្សាកំណើនសមល្មមសម្រាប់ទ្រទ្រង់សកម្មភាពសេដ្ឋកិច្ច ហើយកំណើនេះ អាចសម្រេចបានតាមការគ្រោងទុកក្នុងរង្វង់ ២៦ ភាគរយ ជាប្រចាំឆ្នាំ ។

៣. នៅក្នុងឆមាសទី១ ការនាំចូលសរុបរបស់កម្ពុជាមានទឹកប្រាក់ប្រមាណ ៥.៦៣៥,៥ លានដុល្លារ បានកើនឡើងចំនួន ២០ ភាគរយ ធៀបទៅនឹងឆមាសទី១ ឆ្នាំ ២០១៤ ក្នុងនោះ ការនាំចូលផលិតផលវាយនភ័ណ្ឌកើនឡើង ១៩,៥ ភាគរយ គ្រឿងយន្តកើនឡើង ៣១ ភាគរយ ប្រេងឥន្ធនៈកើនឡើង ៩,១ ភាគរយ បរិក្ខាសំណង់កើនឡើង ១៦,៤ ភាគរយ និងការនាំចូលផលិតផលផ្សេងៗ បានកើនឡើង ២១,៤ ភាគរយ ។ ប្រការនេះ គឺដោយសារតម្រូវការនៅមានសន្ទុះកើនឡើងខ្លាំងនៅឆមាសទី១កន្លងមក ទាំងតម្រូវការប្រើប្រាស់ និង តម្រូវការសម្រាប់ផលិតកម្ម ។

៤. រយៈពេល៦ខែដើមឆ្នាំ ២០១៥ ចំណូលក្នុងស្រុកអនុវត្តបានចំនួន ៥.៩២៧,៣៧ ពាន់លានរៀល គឺខ្ពស់ជាង ៣,១៧ ភាគរយ នៃច្បាប់ថវិកាសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ និងបានកើនឡើង ១៧,១៦ ភាគរយ បើ

ធៀបទៅនឹងរយៈពេលដូចគ្នានៅឆ្នាំ ២០១៤ ។ ចំណូលចរន្តអនុវត្តបាន ៥.៨៩០,៥២ ពាន់លានរៀល គឺខ្ពស់ជាង ៣,៤៨ ភាគរយ នៃច្បាប់ថវិកាសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ និងបានកើនឡើង ១៧,១២ ភាគរយ គឺដោយសារការកើនឡើងនៃចំណូលសារពើពន្ធប្រមាណ ២១,០១ ភាគរយ បើធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៤ ។ ការអនុវត្តចំណាយមានល្បឿនយឺតជាងឆ្នាំកន្លងទៅ ដោយចំណាយសរុបអនុវត្តបានចំនួន ៣.៥៩១,៧៤ ពាន់លានរៀល គឺ ទាបជាង ២៥,៤០ ភាគរយ នៃច្បាប់ថវិកាសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ឬ បានថយចុះ ២៥,៦៣ ភាគរយ ធៀបទៅនឹងរយៈពេលដូចគ្នាឆ្នាំ ២០១៤ មកពីមានការកែសម្រួលនីតិវិធីមួយចំនួនក្នុងការអនុវត្តថវិកា ប៉ុន្តែ នៅក្នុងឆមាសទី២នេះ សង្កេតជារួម ឃើញមានសន្ទុះលឿនក្នុងការអនុវត្តថវិកា បន្ទាប់ពីការកែសម្រួលនីតិវិធីនានាជាបន្តបន្ទាប់បានប្រសើរឡើង ។ ដូច្នេះ នៅខែ មិថុនា ឆ្នាំ ២០១៥ តុល្យភាពថវិកាចរន្តមានអតិរេកជាសាច់ប្រាក់ចំនួន ៣៦២,១៦ ពាន់លានរៀល និងរយៈពេល៦ខែដើមឆ្នាំ ២០១៥ មានអតិរេកសាច់ប្រាក់ចំនួន ២.២២០,៦៨ ពាន់លានរៀល ។

៥. នៅរយៈពេល៧ខែដើមឆ្នាំ ២០១៥ នេះ សំណើសុំវិនិយោគសរុបទូទាំងប្រទេសមានចំនួន ៨៣ គម្រោង គឺថយចុះ ២៤ គម្រោង ធៀបនឹងរយៈពេលដូចគ្នានាឆ្នាំ ២០១៤ កន្លងទៅ ដែលបានបង្កើតកំលាំងពលកម្មចំនួន ១០៨,១៤១ ពាន់នាក់ និងគិតជាទុនវិនិយោគសរុបមានចំនួន ៣៣៣៩,៧៥ លានដុល្លារ គឺបានកើនឡើង ១៩៩,៩ ភាគរយ ។ ការវិនិយោគបានកំណត់លើគម្រោងក្នុងផ្នែកសំខាន់ៗមួយចំនួន ដូចជា ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម និង កសិឧស្សាហកម្ម ។ គម្រោងអភិវឌ្ឍន៍វិស័យឧស្សាហកម្ម មានការថយចុះ ក្នុងនោះរួមទាំងវិស័យកាត់ដេរផងដែរ ។

៦. នៅរយៈពេល៦ខែដើមឆ្នាំ ២០១៥ នេះ ចំនួនអ្នកធ្វើដំណើរសរុបមានចំនួន ២.៣០១,៩៩ ពាន់នាក់ ឬ បានកើនឡើង ១០០,៦ ពាន់នាក់ ស្មើនឹង ៤,៦ ភាគរយ បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០១៤ កន្លងទៅ ។ អ្នកធ្វើដំណើរតាមផ្លូវអាកាសមានចំនួន ១.២៣០,៩ ពាន់នាក់ ឬ បានកើនឡើង ៨,២ ភាគរយ ដែលក្នុងនោះ អ្នកធ្វើដំណើរតាមអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ បានកើនឡើង ១៤,៩ ភាគរយ និង អ្នកដំណើរតាមអាកាសយានដ្ឋានអន្តរជាតិ

សៀមរាប បានកើនឡើង ៣១,២ ភាគរយ ។ ចំណែកឯអ្នកដំណើរតាមផ្លូវគោកនិងទឹកមានចំនួន ១.០៧១,១ ពាន់នាក់ បានកើនឡើង ០,៦ ភាគរយ ។ កំណើនវិស័យទេសចរស្ថិតក្នុងកម្រិតទាប ដែលមិនរំពឹងថាសម្រេចបានកំណើនខ្ពស់ប្រចាំឆ្នាំដូចប៉ុន្មានឆ្នាំកន្លងមក ដោយសារមានការធ្លាក់ចុះទេសចរពីអឺរ៉ុប ព្រោះសន្ទុះកំណើនសេដ្ឋកិច្ចនៅអឺរ៉ុប មានការយឺតយ៉ាវដែលធ្វើឱ្យប៉ះពាល់ដល់ប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ ។ម្យ៉ាងវិញទៀត សន្ទុះលំហូរទេសចរមកកាន់កម្ពុជាពីតំបន់ផ្សេងៗក៏មិនមានការកើនឡើងខ្ពស់ដែរ ។

៧. រយៈពេល៧ខែដើមឆ្នាំ ២០១៥ នេះ សំណើសុំសាងសង់សរុបទូទាំងប្រទេស មានចំនួន ១.០៥៦ គម្រោងគិតជាទឹកប្រាក់មានចំនួន ៨៩៧ លានដុល្លារ ។ បើគិតជាផ្ទៃក្រឡាមានចំនួន ២,៧២១,៤៧៤ ម៉ែត្រការ៉េ បានថយចុះប្រមាណ ៣៨ ភាគរយ ។ ទោះបីជាសំណង់សាងសង់ថ្មីតិចជាងឆ្នាំទៅក្ដី ក៏សកម្មភាពសាងសង់នៅបន្តដំណើរការទាំងសំណង់រដ្ឋនិងសំណង់ឯកជន ដោយមានការកើនឡើងការនាំចូលបរិក្ខាសំណង់ប្រមាណជា ១៦,៥ ភាគរយ រយៈពេល៧ខែដើមឆ្នាំ ២០១៥ នេះ ។

៨. និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារពិភពលោកនៅខែ កក្កដា ឆ្នាំ ២០១៥ តម្លៃប្រេងឆៅ (WTI) សម្រាប់កិច្ចសន្យាលក់មួយខែខាងមុខ បានថយចុះ ១៤,៩ ភាគរយ ធៀបទៅនឹងខែមុន គឺ ពី ៥៩,៨ ដុល្លារ/ធុង មក ៥០,៩០ ដុល្លារ/ធុង ។ ចំពោះប្រេងឆៅ (Brent) បានថយចុះ ១០, ៣៨ ភាគរយ ធៀបទៅនឹងខែមុន គឺ ពី ៦២,៣៤ ដុល្លារ/ធុង មក ៥៥,៨៧ ដុល្លារ/ធុង ។ ចំពោះអង្ករ នៅទីក្រុងបាងកកអង្ករនាំចេញ (ខ្ទេច ៥ ភាគរយ) បានថយចុះថ្លៃបន្តិចមកនៅត្រឹម ៣៩២ ដុល្លារ/តោន ធៀបទៅនឹងខែមុន ដែលមានតម្លៃ ៣៧៦ ដុល្លារ/តោន និងបានថយចុះជាង ៧,១១ ភាគរយ (៤២២ដុល្លារ/តោន) ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ វៀតណាម

អង្ករនាំចេញ (ខ្ទេច ៥ ភាគរយ) មានតម្លៃ ៣៤៥,៧៥ ដុល្លារ/តោន បានថយចុះ ៩,២៣ ភាគរយ ធៀបទៅនឹងខែមុន ដែលថ្លៃ ៣៨៩ ដុល្លារ/តោន ប៉ុន្តែ បានធ្លាក់ចុះប្រមាណជា ១៧,៨ ភាគរយ បើធៀបនឹងរយៈពេលដូចគ្នា

កាលពីឆ្នាំមុន (៤២០,៨៧ ដុល្លារ/តោន) ។ ដូច្នេះ រយៈពេល៧ខែឆ្នាំ ២០១៥ នេះ ការនាំចេញអង្ករវៀតណាម មានកំណើនតិចតួច ដោយសារបញ្ហាការធ្លាក់ចុះតម្រូវការប្រើប្រាស់ក្នុងស្រុក និងមានការប្រកួតប្រជែងថ្លៃខ្ពស់ ជាមួយនឹងប្រទេសថៃ ។ តាមការសង្កេត ថ្លៃអង្ករ អាចនឹងកើនឡើងបន្តិចវិញ ដោយសារភាពរាំងស្ងួត និងការកើនឡើងតម្រូវការអង្ករ នៅអាស៊ីនិងអាហ្វ្រិច ។ ចំណែកថ្លៃកៅស៊ូ នៅបន្តថយចុះ ដោយសារការថមថយការស្រូបយកពីកំលាំងសេដ្ឋកិច្ចប្រទេសចិន ។

*********

## ៣. ឧបសម្ព័ន្ធ

### សូចនាករនាំមុខ (Leading Indicators)




Source: Customs and Excise Dept.




Source: Customs and Excise Dept.




Source: Min. LMUC




Source: MEF & Int.




Source: MEF & Int.




Source: Ministry of Tourism

# អតិផរណា និង ទុនបំរុងបរទេស (Inflation and Foreign Reserves)


















# អត្រាប្តូរប្រាក់ (Exchange Rate)


















# វិស័យរូបិយវត្ថុ និងធនាគារ (Money and Banking)


















# ការអនុវត្តថវិកា (Budget)


















# វិនិយោគឯកជន និង ការបង្កើតការងារ (Investment and Employment)

**CDC Approval, Fixed Assets and Growth (Mn. $)**




Source: CDC

**CDC Approvals- Fixed Assets by Sectors (Mn. $)**




Source: CDC

**Number of Jobs ('000 person)**




Source: CDC

**Public Investment by Source of Finance (Bn.R)**




Source: MEF

**Net Loans Disbursement (Bn.R)**




Source: MEF

**CDC Approvals, Fixed assets by Sources (Mn. $)**




Source: CDC

# វិស័យពាណិជ្ជកម្ម (Trades)


















**កំណត់សម្គាល់**

កៅស៊ូ÷

- កៅស៊ូ TSR 20 : Technically Specific Rubber ឬហៅបានម្យ៉ាងទៀតថា ISNR 20 : Indian Standards Naturally Rubber ជាប្រភេកៅស៊ូដែលបានកែច្នៃក្នុងកម្រិតខ្ពស់ ប្រើប្រាស់សម្រាប់ផលិតជាកង់ឡាន បំពង់ទឹបជ័រ កម្រាលជ័រ ស្បែកជើង អាវភ្លៀជាដើម។ កៅស៊ូប្រភេទនេះមានកម្រិតស្អិតទាប ហើយងាយស្រួលលាយបញ្ចូលជាមួយសារធាតុដទៃទៀត ដែលធ្វើឱ្យផលិតផលដែលផលិតចេញពីកៅស៊ូនេះមានភាពរឹងមាំ ធន់ និងមិនងាយសឹងរិចរិល។
- Rubber (Asia), RSS3 Grade, Singapore Commodity Exchange Ltd (SICOM) Nearby Contract Beginning 2004; During 2000 To 2003, Singapore RSS1; Previously Malaysia RSS1 [RUBBER1_MYSG] **UNITS:** ($/kg) | **SOURCE:** Singapore Exchange Ltd (SGX Previously SICOM); Bloomberg; Rubber Association Of Singapore Commodity Exchange (RASCE); International Rubber Study Group; Asian Wall Street Journal; World Bank.
- RSS 3 : Ribbed Smoked Sheets ជាប្រភេទកៅស៊ូដែលចំរាញ់ចេញពីដើមដែលមានគុណភាពខ្ពស់។ កៅស៊ូប្រភេទនេះត្រូវបានកែច្នៃហើយមានទ្រង់ទ្រាយជា សន្លឹក និងជាដុំស្ងួត។ RSS 3 ប្រើប្រាស់សម្រាប់ផលិតជា កង់រថយន្ត និងបំពង់ទឹបជ័រ និងស្បែកជើង។ ជាទូទៅវាត្រូវបានគេប្រើប្រាស់ច្រើននៅក្នុងឧស្សាហ៍កម្មផលិតសំបកកង់រថយន្ត ហើយជាង ៥០ភាគរយ នៃផ្នែកសំខាន់របស់ផលិតផលត្រូវបាន ផលិតពីកៅស៊ូនេះ។

ប្រេងឆៅ÷

ប្រេងឆៅដែលបានបង្ហាញក្នុងតារាង ២.០ ជាប្រភេទប្រេងឆៅធនស្រាន (Light Crude Oil) ដែលគេធ្វើការទិញលក់ជាលក្ខណៈកិច្ចសន្យាអនាគត (Future Contract) ។ ប្រេងឆៅនៅក្នុងទីផ្សារអន្តរជាតិមានលក្ខណៈខុសគ្នាទៅតាមប្រភេទដូចជា÷ WTI (West Texas Intermediate) ប្រភេទប្រេងរបស់អាមេរិក, Brent ប្រភេទប្រេងរបស់ អង់គ្លេស និង Dubai ជាប្រភេទប្រេងរបស់ប្រទេសអារ៉ាប់ប៊ីសាអ៊ូឌីត។ ប្រភេទប្រេងឆៅទាំងបីមានលក្ខណៈខុសគ្នាទៅតាម កម្រិតភាព ស្រាលហើយប្រភេទប្រេងឆៅដែលមានភាពស្រាលជាងគេ អាចចំរាញ់ ចេញជាប្រេងឥន្ធនៈបានច្រើន។ API Gravity ត្រូវបានគេប្រើប្រាស់ក្នុងការវាស់វែងភាពស្រាលនៃប្រភេទ ប្រេងឆៅនីមួយៗ។ ប្រភេទប្រេងដែល មានកម្រិត API Gravity កាន់តែខ្ពស់ គឺជាប្រភេទប្រេងដែល កាន់តែស្រាល និងអាចចំរាញ់ចេញជាប្រេងឥន្ធនៈបានច្រើន។

- WTI 40$^{o}$ API
- Brent 38$^{o}$ API
- Dubai 32$^{o}$ API

# និន្នាការសេដ្ឋកិច្ចសង្គម

# Socio-Economic Trends

**ប្រចាំខែ កក្កដា-សីហា ឆ្នាំ ២០១៥**/July-August, 2015


*រៀបចំដោយ*

*នាយកដ្ឋានស្ថិតិ*

*អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ*

*ក្រសួង សេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ*

*Statistics Department*

*General Department of Economic and Public Finance Policy*

*Ministry of Economy and Finance*



*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*១ លោក ឆូវ សុមេធា*

*២ លោក សុខ ខន*

*៣ លោក ហាក់ សុផល*

*ម៉ោងធ្វើការ៖ ៧:០០ ដល់ ១១:០០ ព្រឹក*

*២:០០ ដល់ ៥:០០ រសៀល*

*ទូរស័ព្ទលេខ៖ ០២៣ ៤២៧ ៩១៣*